**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជាបុណ្យព្រះយេស៊ូសោយទិវង្គតនៅភ្នំបូកគោ**
**ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៨**
***ខ្ញុំបានបង្ហើយសព្វគ្រប់អស់ហើយ***

អត្ថបទទី១៖ អស ៥២,១៣៥៣,១២
អត្ថបទទី២៖ ហប ៤,១៤-១៦ និង៥,៧-៩
ដំណឹងល្អ៖ យហ ១៨,១-១៩,៤២

បងប្អូនជាទីស្រឡាញ់!

នៅពេលនេះ យើងរួមគ្នាអង្គុយនៅក្បែរឈើឆ្កាង ព្រះយេស៊ូបានសោយទិវង្គតហើយ។ យើងនឹកឃើញពីម្សិលមិញ ព្រះយេស៊ូនៅជាមួយក្រុមគ្រីស្តទូតដើម្បីជប់លៀងនៅ ព្រះយេស៊ូបានយកនំប៉័ងយើងមានព្រះបន្ទូលថា **នេះជារូបកាយរបស់ខ្ញុំ** និងយកពែងស្រា ហើយមានព្រះបន្ទូលថា **នេះជាលោហិតរបស់ខ្ញុំ**។ នៅពេលនេះ យើងមើលព្រះយេស៊ូដែលសោយទិវង្គតនៅលើឈើឆ្កាង គឺរូបកាយរបស់ព្រះយេស៊ូផ្ទាល់ គឺលោហិតរបស់ព្រះយេស៊ូផ្ទាល់ ដែលបានបូជាជីវិតសម្រាប់យើង។ យើងបានស្តាប់ ការរងទុក្ខលំបាករបស់ព្រះយេស៊ូណែនាំឲ្យយើងគិតពិចារណា អំពីជំនឿរបស់យើងទៅលើព្រះយេស៊ូគ្រីស្ត ប៉ុន្មានដងយើងសួរសំនួរថា **តើព្រះអង្គម្ចាស់ជានរណា ដើម្បីស្រឡាញ់ខ្ញុំដូច្នេះ?** យប់មិញនៅពេលព្រះយេស៊ូជប់លៀងចុងក្រោយ ព្រះយេស៊ូបានបង្ហាញសេចក្តីស្រឡាញ់ដ៏ខ្ពង់ខ្ពស់បំផុត ថ្ងៃនេះព្រះយេស៊ូបានបង្ហាញសេចក្តីស្រឡាញ់ដល់កំពូល គឺព្រះអង្គបូជាជីវិតសម្រាប់មនុស្សលោក។ ពិតមែនព្រះជាម្ចាស់ជានរណា ដើម្បីស្រឡាញ់យើងយ៉ាងនេះ? ថ្ងៃនេះព្រះយេស៊ូមានសំនួរដល់អ្នកដែលមកចាប់ព្រះអង្គ **តើអ្នករាល់គ្នាមករកនរណា?** ខ្ញុំជឿថានេះក៏ជាសំណួរសម្រាប់យើងម្នាក់ៗរៀងៗខ្លួន ដែលព្រះយេស៊ូបានសួរយើងម្នាក់ៗថា តើអ្នករាល់គ្នាមករកនរណា? នៅពេលនេះយើងអង្គុយនៅក្នុងព្រះវិហារលើភ្នំបូកគោនេះ យើងត្រូវការស្តាប់សំនួរនេះ តើយើងមករកនរណា? ប្រហែលយើងអាចឆ្លើយដូចគេដែរ យើងមករកឈ្មោះយេស៊ូ ជាអ្នកភូមិណាសារ៉ែត ដែលជាមនុស្សសុចរិតដោយបានធ្វើដំណើរជាមួយប្រជារាស្ត្របីឆ្នាំ ដើម្បីណែនាំឲ្យគេមានជីវិត ដើម្បីណែនាំឲ្យគេមានសេចក្តីសង្ឃឹម។ យេស៊ូ ជាអ្នកភូមិណាសារ៉ែត ដែលធ្វើដំណើរជាមួយយើងជារៀងរាល់ថ្ងៃ ដែលចាប់ដៃយើងជារៀងរាល់ថ្ងៃ ដើម្បីឲ្យយើងមានជីវិត ដើម្បីឲ្យយើងមានសេចក្តីសង្ឃឹម ដើម្បីឲ្យយើងមានកម្លាំងកាយកម្លាំងចិត្ត។ យើងមករកយេស៊ូ ជាអ្នកភូមិណាសារ៉ែត នៅពេលនេះព្រះយេស៊ូឆ្លើយតប

ដល់យើង **គឺខ្ញុំហ្នឹងហើយ**។ នៅពេលយើងសម្លឹងមើល ព្រះឈើឆ្កាង យើងនឹកឃើញព្រះយេស៊ូដែលមានព្រះបន្ទូលដល់យើង **គឺខ្ញុំហ្នឹងហើយ**។ នៅថ្ងៃដែលព្រះយេស៊ូយាងចូលទីក្រុងយេរ៉ូសាឡឹម ប្រជារាស្ត្របានកោតសរសើរព្រះអង្គ **ជយោ! ព្រះរាជ្យវង្សព្រះបាទដាវីឌ**។ ព្រះយេស៊ូ ដែលជាព្រះមហាក្សត្ររបស់ជនជាតិយូដា ព្រះយេស៊ូ ដែលជាព្រះមហាក្សត្ររបស់យើង ព្រះយេស៊ូដែលបានណែនាំយើងឲ្យយើងទទួលជីវិត សេចក្ដីសង្ឃឹម។ ថ្ងៃនេះលោកពីឡាតបានសួរព្រះអង្គថា **តើអ្នកជាស្ដេចរបស់ជនជាតិយូដាមែនឬ?**

យើងមករកឃើញនរណា? រកឃើញឈ្មោះយេស៊ូជាអ្នកភូមិណាសារ៉ែត លើសពីនេះទៀត យើងមករកយេស៊ូដែលបានណែនាំឲ្យយើងមានសេចក្ដីសង្ឃឹម យើងមករកយេស៊ូដែលបានណែនាំឲ្យយើងរកឃើញអនាគតដ៏ភ្លឺស្វាងរបស់យើង យើងមករកយេស៊ូដែលយើងសង្ឃឹមថាជាព្រះមហាក្សត្រដែលអាចគ្រប់គ្រងយើង ដើម្បីណែនាំឲ្យជីវិតរបស់យើងលើលោកនេះ ឲ្យទៅជាជីវិតមួយដែលពោរពេញដោយយុត្តិធម៌ ពោរពេញដោយការយល់ចិត្តគ្នា ពោរពេញដោយសេចក្ដីស្រឡាញ់រវាងគ្នានឹងគ្នា។ ប៉ុន្តែថ្ងៃនេះ ព្រះយេស៊ូមានព្រះបន្ទូលមួយផ្សេងទៀត **ព្រះរាជ្យរបស់ខ្ញុំមិនមែននៅក្នុងលោកនេះទេ** ព្រះយេស៊ូដែលយើងរកឃើញដែលជាអ្នកភូមិណាសារ៉ែត មិនមែនជាព្រះមហាក្សត្រតាមលោកីយ៍ មិនមែនព្រះមហាក្សត្រដែលយើងទន្ទឹងរង់ចាំនៅក្នុងចិត្តរបស់យើង ជាព្រះមហាក្សត្រមួយយ៉ាងពិសេស។ ព្រះយេស៊ូមានព្រះបន្ទូលថា ខ្ញុំកើតមក ហើយខ្ញុំមកក្នុងលោកនេះ **ដើម្បីផ្ដល់សក្ខីភាពអំពីសេចក្ដីពិត** ព្រះមហាក្សត្ររបស់យើងមិនមកពីលោកនេះទេ គឺមកពីព្រះជាម្ចាស់ ដើម្បីសម្ដែងបញ្ជាក់អំពីសេចក្ដីពិត។ លោកពីឡាត បានសួរថា **អ្វីជាសេចក្ដីពិត?** ព្រះយេស៊ូនៅស្ងៀមស្ងាត់។

នៅពេលនេះយើងបិទភ្នែករបស់យើង ដើម្បីចូលយ៉ាងជ្រៅនៅក្នុងបទពិសោធន៍របស់យើងជាមួយព្រះយេស៊ូ។ ព្រះយេស៊ូដែលបានណែនាំឲ្យយើងមានជីវិត នៅថ្ងៃដែលយើងបានទទួលអគ្គសញ្ញាជ្រមុជទឹក ព្រះយេស៊ូដែលបានណែនាំឲ្យយើងមានជីវិត ជារៀងរាល់ពេលយើងទទួលអគ្គសញ្ញាព្រះកាយព្រះគ្រីស្ត ព្រះយេស៊ូដែលបានណែនាំឲ្យយើងមានជីវិត នៅពេលយើងទទួលអគ្គសញ្ញាលើកលែងទោស ព្រះយេស៊ូដែលបានណែនាំឲ្យយើងមានជីវិត នៅពេលយើងណែនាំឲ្យជំនឿរបស់យើងប្រព្រឹត្តអំពើល្អ ស្រឡាញ់ បម្រើ លើកទឹកចិត្ត ផ្ដល់កម្លាំងដល់បងប្អូនឯទៀតៗ ជាពិសេសអ្នកតូចតាចដែលគ្មានសេចក្ដីស

ង្សឹម។ យើងត្រូវការបិទភ្នែករបស់យើងដែលមើលឃើញលោកីយ៍ ដើម្បីបើកភ្នែកនៃជំនឿឲ្យយើងមើលជំនឿរបស់យើង។ នៅពេលយើងនៅក្បែរឈើឆ្កាង យើងចាប់ផ្តើមយល់អំពីជំនឿរបស់យើង ព្រះយេស៊ូមានព្រះបន្ទូលដល់ព្រះនាងម៉ារីថា **អ្នកអើយ! នេះហើយកូនរបស់អ្នក** ដល់លោកយ៉ូហានថា **នេះហើយម្តាយរបស់អ្នក** នៅពេលនោះព្រះយេស៊ូណែនាំឲ្យបង្កើតពិភពថ្មី ដែលព្រះនាងម៉ារី លោកយ៉ូហាន ជានិម្មិតសញ្ញាយ៉ាងពិសេស ពិភពលោកថ្មីនេះជាពិភពលោកដែលគ្មានព្រំដែន។

នៅពេលព្រះយេស៊ូនៅលើឈើឆ្កាង ណែនាំឲ្យបំផ្លាញព្រំដែនដែលយើងដាក់នៅក្នុងចិត្តគំនិតរបស់យើង ព្រំដែនដែលណែនាំឲ្យយើងមានចិត្តចង្អៀតចង្អល់។ យប់នេះព្រះយេស៊ូទ្រង់បំផ្លាញ គ្រប់ព្រំដែនដែលណែនាំឲ្យមនុស្សយើងខ្វះសេចក្តីស្រឡាញ់។ នៅពេលនេះយើងសម្លឹងមើល ព្រះយេស៊ូ ព្រះនាងម៉ារី លោកយ៉ូហាន ដែលជាសញ្ញាសម្គាល់នៃពិភពថ្មីដែលគ្មានព្រំដែន ជាសញ្ញាសម្គាល់នៃព្រះរាជ្យរបស់ព្រះជាម្ចាស់ ព្រះនាងម៉ារីដែលចាប់ដៃយើង ដើម្បីឲ្យយើងធ្វើដំណើរនៅក្នុងព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់។ នៅពេលព្រះយេស៊ូ កំពុងបំផ្លាញគ្រប់ព្រំដែនដែលណែនាំឲ្យពិភពនិងដួងចិត្តរបស់យើង ទៅជាពិភពនិងដួងចិត្តចង្អៀតចង្អល់ ព្រះយេស៊ូមានព្រះបន្ទូលថា **ខ្ញុំស្រេកទឹក!**។ ព្រះយេស៊ូកំពុងមើលពិភពលោករបស់យើង ពិភពដែលពោរពេញដោយសង្គ្រាម ពិភពដែលពោរពេញដោយអយុត្តិធម៌ ពិភពដែលពោរពេញដោយអ្នកក្រីក្រដែលគ្មានទីពឹង ពិភពដែលពោរពេញដោយមនុស្សដែលមានអំណាចជិះជាន់អ្នកតូចតាច ពិភពដែលពោរពេញដោយស្ត្រីមេម៉ាយ ក្មេងកំព្រាដែលគ្មានឪពុកម្តាយដើម្បីផ្តល់សេចក្តីស្រឡាញ់ ពិភពដែលពោរពេញដោយការឈឺចាប់ ការទុក្ខលំបាកអស់សង្ឃឹម ព្រះយេស៊ូស្រែកឡើងថា ខ្ញុំស្រេកទឹក គឺស្រេកទឹកនៃជីវិត ស្រេកទឹកនៃសេចក្តីស្រឡាញ់ ស្រេកទឹកនៃការលើកលែងទោស។ នៅពេលនេះ ព្រះយេស៊ូដែលកំពុងបង្កើតពិភពថ្មីដែលគ្មានព្រំដែន ដែលមានតែសេចក្តីស្រឡាញ់ដ៏ធំធេង។ ព្រះយេស៊ូ ណែនាំឲ្យយើងចូលនៅក្នុងគម្រោងការណ៍ដ៏អស្ចារ្យរបស់ព្រះអង្គ ដោយសារនៅពេលនេះមិនមែនតែព្រះនាងម៉ារី មិនមែនតែលោកយ៉ូហាន នៅពេលនេះគឺខ្ញុំជាគ្រីស្តបរិស័ទ យើងជាព្រះសហគមន៍ ដែលអង្គុយនៅក្បែរឈើឆ្កាងរបស់ព្រះយេស៊ូ ដែលសម្លឹងមើលព្រះយេស៊ូ ដែលស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូ ខ្ញុំស្រេកទឹក។

ព្រះយេស៊ូ អញ្ជើញយើងឲ្យយើងក្រោកឈរឡើង ដើម្បីទៅជាសញ្ញានៃពិភពដែលពោរពេញដោយសេចក្តីស្រឡាញ់ សេចក្តីសង្ឃឹម និងយុត្តិធម៌ ពិភពដែលគ្មានព្រំដែន។

ដល់ពេលវេលាហើយ ព្រះយេស៊ូបានបំពាក់បេសកកម្មរបស់ព្រះអង្គលើផែនដីនេះ មានន័យថាព្រះយេស៊ូបានណែនាំឲ្យសម្ព័ន្ធមេត្រីថ្មី រវាងយើងជាមនុស្សទន់ខ្សោយ ជាមនុស្សពោរពេញដោយអំពើបាប ជាមួយព្រះជាម្ចាស់ដ៏មានរិទ្ធានុភាពសព្វប្រការ ឲ្យទៅជាសម្ព័ន្ធមេត្រីដ៏ស្ថិតស្ថេរនៅលើឈើឆ្កាងនេះ។ យើងនៅស្ងៀមស្ងាត់ ដោយសម្លឹងមើលព្រះឈើឆ្កាង និងយើងស្តាប់ព្រះបន្ទូលចុងក្រោយរបស់ព្រះយេស៊ូ **ខ្ញុំបានបង្ហើយសព្វគ្រប់អស់ហើយ**។ អាម៉ែន។